# ព័ត៌មានថ្មីៗ

**Leon Bignell MP**
រដ្ឋមន្ត្រីក្រសួងកសិកម្ម ស្បៀងអាហារ និងនេសាទ

ថ្ងៃច័ន្ទ ទី៣ ខែតុលា ឆ្នាំ២០១៦

**ជំនួយសម្រាប់អ្នកផលិតវត្ថុធាតុដើមដែលបានរងប៉ះពាល់ដោយទឹកជំនន់**

រដ្ឋាភិបាលប្រចាំរដ្ឋ បានបង្កើតខ្សែទូរស័ព្ទទាន់ហេតុការណ៍មួយសម្រាប់អ្នកផលិតវត្ថុធាតុដើមដែលបានរងប៉ះពាល់ដោយទឹកជំនន់ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងថ្មីៗនេះ។

ក្រសួងឧស្សាហកម្មវត្ថុធាតុដើម និងតំបន់ភូមិភាគ SA (PIRSA) នឹងចាត់ចែងការវាយតម្លៃខ្សែទូរស័ព្ទទាន់ហេតុការណ៍នេះដែលនឹងប្រតិបត្តិការ២៤ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍។

ទឹកជំនន់នៅទន្លេ Gawler River បានប៉ះពាល់យ៉ាងច្រើនបំផុតដល់អ្នកផលិតវត្ថុធាតុដើមដោយមានដីចំការប្រមាណ១០០០ហិកតានៅតំបន់សារប្បកម្ម Northern Adelaide Plains (ដីទំនាបនៅតំបន់ភាគខាងជើងក្រុងអាដឺឡែត) ត្រូវបានលិចដោយទឹកជំនន់។

ការវាយតម្លៃនៅលើតំបន់កំពុងបន្ត ដោយមានមន្ត្រី PIRSA មួយចំនួនកំពុងធ្វើការជាមួយក្រុមឧស្សាហកម្ម រួមមាន Primary Producers SA (អ្នកផលិតវត្ថុធាតុដើម SA) និង Horticulture Coalition of SA (សម្ព័ន្ធសាកវប្បកម្ម SA) ដើម្បីកំណត់ពីទំហំនៃការខូចខាតនេះ។

អ្នកផលិតវត្ថុធាតុដើមដែលត្រូវការជំនួយ គួរទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍របស់ PIRSA លេខ (08) 8207 7847។ ព័ត៌មានបន្ថែមទាក់ទិនទឹកជំនន់ និងខ្យល់ព្យុះសម្រាប់អ្នកផលិតវត្ថុធាតុដើម អាចទទួលយកបាននៅតាមវិបសាយរបស់ PIRSA នៅត្រង់ www.pir.sa.gov.au

**សម្រង់ចេញពីរដ្ឋមន្ត្រីក្រសួងកសិកម្ម ស្បៀងអាហារ និងនេសាទ លោក Leon Bignell**

ខណៈពេលដែលអាកាសធាតុសើមជោគនេះកំពុងតែបន្ត ភាពជាក់លាក់នៃផលប៉ះពាល់បណ្ដាលមកពីព្រឹត្តិការណ៍ប៉ុន្មានថ្ងៃចុងក្រោយនេះសម្រាប់អ្នកផលិតវត្ថុធាតុដើមរបស់រដ្ឋនៅតែមិនទាន់ច្បាស់ប្រាកដនៅឡើយ ក៏ប៉ុន្តែការចង្អុលបង្ហាញនោះគឺថាតំបន់សាកវប្បកម្ម Northern Adelaide នៃតំបន់ទំនាបភាគខាងជើងក្រុងអាដឺឡែត គឺជាតំបន់ដែលរងប៉ះពាល់ច្រើនបំផុត។

ការប៉ាន់ប្រមាណនៃការខាតបង់នៅតំបន់នេះគឺរវាងពី២០-៣០លានដុល្លា បើទោះជាទឹកជំនន់នៅតែខ្ពស់ក្ដីនៅក្នុងតំបន់នេះ វាទំនងជាត្រូវការពេលពីរបីថ្ងៃទៀត ទំរាំតែទំហំពេញលេញនៃការបំផ្លិចបំផ្លាញនេះត្រូវបានដឹងច្បាស់ប្រាកដ។

ពាក្យណែនាំដែលយើងបានទទួលនោះគឺថា វានឹងត្រូវការពេលប្រាំមួយខែដើម្បីឱ្យតំបន់នេះអាចងើបរួចឡើងវិញ ជាមួយនឹងបញ្ហាប្រឈមដែលកំពុងបន្ត រួមមានបរិមាណគ្រាប់ពូជដើម្បីដាំដំណាំឡើងវិញ ភាពមានផ្ដល់នៃថ្នាំសម្លាប់ផ្សិតដើម្បីព្យាបាលដំណាំដែលនៅសេសសល់ ព្រមទាំងការដុះកើនឡើងនៃស្មៅ ហើយនិងការស៊ីបំផ្លាញនៃសត្វល្អិតចង្រៃ។

នៅកន្លែងផ្សេងទៀត យើងដឹងថាការខូចខាតហេដ្ឋារចនាសម្ព័ន្ធដែលបានកើតឡើងពេញទូទាំងរដ្ឋ រួមមានកន្លែងកាត់រោមសត្វ ស្មៅស្ងួត ចំបើង និងរោងដាក់គ្រឿងម៉ាស៊ីន ដើមឈើរលំនៅលើរបង ផ្លូវ និងបង្គោលខ្សែភ្លើង។ ម្ចាស់ដីអាចជួបប្រទះការចំណាយយ៉ាងច្រើនក្នុងការបោសសម្អាតបន្ទាប់ពីព្រឹត្តិការណ៍នៃទឹកជំនន់ និងខ្យល់ព្យុះទាំងនេះ ។

ការចង្អុលបង្ហាញពីវិស័យឧស្សាហកម្មវត្ថុធាតុដើមផ្សេងទៀតរហូតមកដល់ពេលនេះគឺថា ការខាតបង់បសុសត្វគឺមានតិចតួច ជាមួយនឹងការខូចខាតធញ្ញជាតិ និងដំណាំនៅតាមទីកន្លែងខ្លះៗដោយសារធ្លាក់ដុំព្រិល ឬការលិចលង់ ជាពិសេសនៅតំបន់ Eyre Peninsula។ ការប៉ាន់ប្រមាណនៃជាផលដំណាំបច្ចុប្បន្នគឺ៨.៩លានតោននាពេលបច្ចុប្បន្ន ត្រូវបានរំពឹងទុកថាមិនមានចំនួនតិចជាងនេះទៀតទេក្នុងដំណាក់កាលនេះ។

ដោយសារតែស្ថានភាពសើមជោគ ជាមួយនឹងអាកាសធាតុក្ដៅដែលត្រូវបានរំពឹងទុកនៅចុងសប្ដាហ៍នេះ ភាពប្រឈមនៃការកើតមានសត្វល្អិតចង្រៃ និងជំងឺ ឥឡូវនេះមានកម្រិតខ្ពស់ណាស់។ រដ្ឋាភិបាលប្រចាំរដ្ឋកំពុងធ្វើការជាមួយវិស័យឧស្សាហកម្មវត្ថុធាតុដើមទាំងអស់ ដើម្បីធានាថាអ្នកផលិតវត្ថុធាតុដើមរបស់យើង នឹងដំណើរការឡើងវិញជាយ៉ាងឆាប់ តាមដែលអាចធ្វើទៅបាន។

ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន៖ Callie Bryson 0478 346 495